**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :.........០០៨/២២..........ក.ប/ស.ជ.ណា.ម.ហ

# សេចក្តីជូនដំណឹង
## ស្តីពី
## នីតិវិធីសម្រាប់កម្មសិក្សាការី-ពលករជំនាញកម្ពុជាទៅធ្វើការនៅប្រទេសជប៉ុន ស្របតាមវិធានការព្រំដែនថ្មីរបស់រាជរដ្ឋាភិបាលនៃប្រទេសជប៉ុន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់សាធារណជន ទីភ្នាក់ងារជ្រើសរើសឯកជន និងកម្មសិក្សាការី-ពលករជំនាញ ដែលត្រៀមចេញដំណើរទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុនទាំងអស់ឱ្យបានជ្រាបថា រដ្ឋាភិបាលនៃប្រទេសជប៉ុន បានសម្រេចអនុញ្ញាតឱ្យជនបរទេស រួមទាំងកម្មសិក្សាការី-ពលករជំនាញកម្ពុជា ចូលប្រទេសជប៉ុនឡើងវិញ **ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២** នេះតទៅ ដោយត្រូវអនុវត្តទៅតាមនីតិវិធីដូចខាងក្រោម៖

❖ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវ៖

១. សហការជាមួយក្រុមហ៊ុនទទួល ឬសមាគមនៅប្រទេសជប៉ុន ដើម្បីស្នើសុំលិខិតអនុញ្ញាតបន្ថែមសម្រាប់កម្មសិក្សាការី-ពលករជំនាញចូលប្រទេសជប៉ុន តាមរយៈប្រព័ន្ធ Entrants, Returnees Follow-up System របស់ប្រទេសជប៉ុន

២. បន្ទាប់មក ត្រូវភ្ជាប់បន្ថែមនូវលិខិតអនុញ្ញាតនេះសម្រាប់កម្មសិក្សាការី-ពលករជំនាញ នៅពេលស្នើសុំទិដ្ឋាការជូនកម្មសិក្សាការី-ពលករជំនាញ នៅស្ថានទូតជប៉ុនប្រចាំកម្ពុជា។

❖ កម្មសិក្សាការី-ពលករជំនាញត្រូវ៖

១. ត្រូវមានវិញ្ញាបនបត្របញ្ជាក់ថាគ្មានមេរោគកូវីដ-១៩ រយៈពេល៧២ម៉ោង មុនចេញដំណើរ។

២. បំពេញកិច្ចសន្យាអនុវត្តវិធានការចត្តាឡីស័ក ដែលតម្រូវដោយរាជរដ្ឋាភិបាលនៃប្រទេសជប៉ុន មុនពេលចាកចេញទៅប្រទេសជប៉ុន។

៣. ទាញយកកម្មវិធី Covid-19 Contact-Confirming Application ទៅក្នុងទូរស័ព្ទដៃ និងចុះឈ្មោះក្នុងកម្មវិធី មុនពេលចាកចេញទៅប្រទេសជប៉ុន។

៤. ផ្តល់កិច្ចសន្យាអនុវត្តវិធានការចត្តាឡីស័ក ជូនការិយាល័យទទួលបន្ទុកអនុវត្តចត្តាឡីស័កនៅអាកាសយានដ្ឋានប្រទេសជប៉ុន។

៥. អនុវត្តវិធានការរបស់រដ្ឋាភិបាលជប៉ុនដូចខាងក្រោម៖

- អ្នកបានចាក់វ៉ាក់សាំងដែលទទួលស្គាល់ដោយប្រទេសជប៉ុនចំនួន៣ដូស៖ ត្រូវធ្វើចត្តាឡីស័កចំនួន៣ថ្ងៃ នៅកន្លែងខ្លួនឯង និងធ្វើតេស្តរកមេរោគកូវីដ-១៩ នៅថ្ងៃទី៣។
- អ្នកមិនបានចាក់វ៉ាក់សាំងដែលទទួលស្គាល់ដោយប្រទេសជប៉ុនចំនួន៣ដូស៖ ត្រូវធ្វើចត្តាឡីស័កចំនួន៣ថ្ងៃ នៅកន្លែងដែលកំណត់ដោយការិយាល័យចត្តាឡីស័ក មិនអនុញ្ញាតឱ្យប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ និងធ្វើតេស្តរកមេរោគកូវីដ-១៩ នៅថ្ងៃទី៣។

***<u>សម្គាល់៖</u>*** *ក្នុងករណីដែលកម្មសិក្សាការី-ពលករជំនាញ មិនអនុវត្តតាមគោលការណ៍ណែនាំនៅប្រទេសជប៉ុន អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសជប៉ុន នឹងចាត់វិធានការតាមផ្លូវច្បាប់។*

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ទីភ្នាក់ងារជ្រើសរើសឯកជន និងកម្មសិក្សាការី-ពលករជំនាញ ដែលត្រៀមចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុនទាំងអស់ ជ្រាបជាព័ត៌មាន និងសហការអនុវត្តឱ្យមានប្រសិទ្ធភាព។

ថ្ងៃ សុក្រ ២កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**<u>ចម្លងជូន</u>**

-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)

-សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)

-ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់

"ដើម្បីជួយផ្សព្វផ្សាយ និងសហការ"

-ឯកសារ-កាលប្បវត្តិ